**ស្ថានទូតអូស្ត្រាលី**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

## សេចក្តីប្រកាសព័ត៌មាន

ថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០២៣

## កិច្ចពិគ្រោះយោបល់អន្តរក្រសួងទៅលើផែនការភាពជាដៃគូនៃកិច្ចសហប្រត្តិបត្តិការអភិវឌ្ឍន៍ថ្មី របស់ប្រទេសអូស្ត្រាលីជាមួយប្រទេសកម្ពុជា

ថ្ងៃនេះ ឯកឧត្តម រិត វុទ្ធី អគ្គលេខាធិការនៃគណកម្មាធិការសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និង ឯកឧត្តម ចាស្ទីន វ៉ាយអេត ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំកម្ពុជា បានធ្វើកិច្ចពិគ្រោះយោបល់ជាមួយក្រសួងរបស់រាជរដ្ឋាភិបាលកម្ពុជា ចំនួន១៤ ទៅលើផែនការភាពជាដៃគូនៃកិច្ចសហប្រត្តិបត្តិការអភិវឌ្ឍន៍ថ្មី របស់ប្រទេសអូស្ត្រាលីសម្រាប់ប្រទេសកម្ពុជា។

ឯកឧត្តម ចាស្ទីន វ៉ាយអេត បានមានប្រសាសន៍ថា "កិច្ចពិគ្រោះយោបល់ជាផ្នែកមួយនៃការពិភាក្សាជាបន្តបន្ទាប់ ដែលយើងកំពុងមាន ក្នុងពេលដែលយើងកំពុងបង្កើត ផែនការភាពជាដៃគូនៃកិច្ចសហប្រត្តិបត្តិការអភិវឌ្ឍន៍ថ្មី ដើម្បីកំណត់ទិសដៅរយៈពេលវែង នៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់យើង ជាមួយប្រទេសកម្ពុជា។ យើងកំពុងពិគ្រោះយោបល់ជាមួយ រដ្ឋាភិបាលកម្ពុជា បណ្ឌិត្យសភា ធុរកិច្ច សង្គមស៊ីវិល និងដៃគូអភិវឌ្ឍន៍ផ្សេងៗ ដើម្បីស្វែងរកយោបល់ និងទស្សនៈរបស់ពួកគេ»។

កាលពីខែសីហាឆ្នាំនេះ ប្រទេសអូស្ត្រាលីបានចេញផ្សាយគោលនយោបាយអភិវឌ្ឍន៍អន្តរជាតិថ្មី ដែលកំណត់នូវអទិភាពចំនួនជាង៣០ ដើម្បីផ្តល់នូវកម្មវិធីដែលមានប្រសិទ្ធភាព ឆ្លើយតប មានតម្លាភាព និងគណនេយ្យភាពជាងមុន។ ក្នុងចំណោមអទិភាពសំខាន់ៗរបស់ខ្លួន គោលនយោបាយនេះបានកំណត់គោលដៅ និងសកម្មភាព ទៅលើ ការប្រែប្រួលអាកាសធាតុ សមភាពយេនឌ័រ ការគាំទ្រការអភិវឌ្ឍដែលដឹកនាំដោយកម្ពុជាផ្ទាល់ និងវិធីសាស្រ្តពង្រឹងឡើងវិញលើផែនការយុទ្ធសាស្រ្តរបស់ប្រទេស។

ឯកឧត្តម ចាស្ទីន វ៉ាយអេត បានបន្ថែមថា «ក្នុងរយៈពេលប្រាំទសវត្សរ៍កន្លងមកនេះ អូស្ត្រាលីបានផ្តល់ជំនួយអភិវឌ្ឍន៍ជាផ្លូវការ ជិត២ពាន់លានដុល្លារដល់កម្ពុជា។ ជំនួយទាំងនេះ ភាគច្រើនបានជួយដល់កិច្ច

ខិតខំប្រឹងប្រែងរបស់កម្ពុជា ដែលមានតាំងពីដើមទសវត្សរ៍ឆ្នាំ១៩៩០ ក្នុងការស្តារឡើងវិញនូវ ហេដ្ឋារចនាសម្ព័ន្ធ ការដោះមីន កសិកម្ម សុខាភិបាល និងការអប់រំ។ ប៉ុន្តែប្រទេសកម្ពុជាបានមកដល់ចំនុចឆ្ងាយហើយ ហើយបរិបទនៃជំនួយអភិវឌ្ឍន៍របស់យើងក៏ខុសពីមុនច្រើនដែរ។

ផែនការភាពជាដៃគូនៃកិច្ចសហប្រត្តិបត្តិការអភិវឌ្ឍន៍ថ្មី ជាឱកាសមួយសម្រាប់យើង ក្នុងការពិនិត្យឡើងវិញ ស្តាប់ដៃគូរបស់យើង និងកំណត់គោលដៅរបស់យើង ដើម្បីធានាថា យើងកំពុងឆ្លើយតបទៅនឹងបញ្ហាធំៗដែលកម្ពុជាកំពុងប្រឈម និងបង្កើនប្រសិទ្ធភាពនៃកម្មវិធីកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍របស់យើង»។

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au